**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**ភាគីដាក់ឯកសារ:** មេធាវីការពារក្តីរបស់ មាស មុត

**ដាក់ជូន:** សហចៅក្រមស៊ើបអង្កេត

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០១៣

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ:**

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

**សំណើរបស់ មាស មុត**

**សុំការពន្យល់បំភ្លឺទាក់ទងនឹងស្ថានភាពនៃការស៊ើបអង្កេតរបស់តុលាការ**

---

**<u>ដាក់ដោយ:</u>**

**សហមេធាវី**

អាង ឧត្តម
Michael G. KARNAVAS

**<u>ចម្លងជូន:</u>**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIA

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យបញ្ជាក់ពីស្ថានភាពបច្ចុប្បន្ននៃការស៊ើបអង្កេតរបស់តុលាការ ជាពិសេសទាក់ទងនឹង (ក) តើការស៊ើបអង្កេតនៅបន្តបើក ឬបិទហើយនៅពេលនេះ (ខ) ចរិតលក្ខណៈទូទៅនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតដែលបានកើតឡើងក្នុងខែកុម្ភៈ ឆ្នាំ ២០១៣ កន្លងទៅ (គ) សំអាងហេតុលើការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតម្នាក់ៗ (ឃ) តើមានការខ្វែងយោបល់គ្នាជាផ្លូវការដទៃផ្សេងទៀតទេ រវាងសហចៅក្រមស៊ើបអង្កេតកន្លងមក និង (ង) តើការខ្វែងយោបល់គ្នានោះ (ឬទាំងនោះ) ត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះហើយឬនៅ? បើមិនទាន់សម្រេចនៅឡើយទេ តើពេលណាគេអាចរំពឹងថាអង្គបុរេជំនុំជម្រះនឹងចេញសេចក្តីសម្រេចនោះ? លើសពីនេះទៀត ក្រុមមេធាវីក៏ស្នើសុំដល់ ក.ស.ច.ស ឲ្យផ្តល់ព័ត៌មានទាក់ទងទៅនឹងការប្រែប្រួលណាមួយលើស្ថានភាពនៃការស៊ើបអង្កេតរបស់តុលាការ។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ដើម្បីអនុញ្ញាតឲ្យមេធាវីអាចការពារបានពេញលេញ នូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក មាស មុត។ ទោះបីជា សំណើនេះអាចមានលក្ខណៈស្រដៀងគ្នាខ្លះទៅនឹងសំណើមុនៗដែលធ្វើឡើងដោយ មាស មុត[១] ក៏ដោយ ក៏សំណើនេះមិនមែនជាសំណើច្រំដែលនោះឡើយ។ ព័ត៌មានដែលបានស្នើសុំនៅក្នុងសំណើនេះមិនមាននៅក្នុងសំណើមុនៗឡើយ។ សំណើនេះអាចទទួលយកបាន អនុលោមតាមវិធាន ២១ ដែលចែងថា “ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ... កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ត្រូវធ្វើឡើងប្រកបដោយតម្លាភាព និងយុត្តិធម៌...។” ក្រុមមេធាវីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេសសិន ដោយឯកសារបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនពេលក្រោយ ដោយហេតុថា អង្គភាពបកប្រែភាសាមិនអាចបកប្រែឯកសារនេះចប់ទាន់ពេលវេលាបាន[២]។

---

[១] *សូមមើល* សំណើរបស់ មាស មុត ស្នើសុំការអនុញ្ញាតចូលមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៣ ឯកសារ D82។ សំណើរបស់ មាស មុត ស្នើសុំព័ត៌មានទាក់ទងនឹងវិធីសាស្ត្រ និងអភិក្រមស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២ ខែតុលា ឆ្នាំ២០១៣។

[២] *សូមមើល* អ៊ីម៉ែលពីអង្គភាពបកប្រែភាសា ផ្ញើមកក្រុមមេធាវីការពារក្តី “កម្មវត្ថុ: សំណើរសុំសេវាបកប្រែភាសា” ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៣។

## I. **សាវតារ**

1. នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ក.ស.ព បានផ្តួចផ្តើមការស៊ើបអង្កេតលើ លោក មាស មុត តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ២ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ ក.ស.ព ពាក់ព័ន្ធនឹងកងទ័ពបដិវត្តកម្ពុជា[៣]។
2. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ប្រហែលជិត ២០ ខែ បន្ទាប់ពីការស៊ើបអង្កេតនេះបានចាប់ផ្តើម សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Siegfried Blunk បានចេញសេចក្តីជូនដំណឹងស្តីពីការបិទបញ្ចប់ការស៊ើបអង្កេតរបស់តុលាការលើសំណុំរឿង ០០៣[៤]។
3. នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត Blunk បានដាក់ពាក្យសុំលាលែង ចាប់ពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១១[៥]។
4. នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet បានចេញដីកាមួយបើកការស៊ើបអង្កេតបន្តទៀត។ គាត់បានបញ្ជាក់ថា ការស៊ើបអង្កេតកន្លងមកហាក់មានវិការៈ និងប៉ះពាល់ដល់ប្រយោជន៍របស់គ្រប់ភាគីទាំងអស់[៦]។
5. នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet បានដាក់ការខ្វែងយោបល់គ្នាជាមួយសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង។ ចរិតលក្ខណៈពិតប្រាកដនៃការខ្វែងយោបល់គ្នានេះមិនមានភាពច្បាស់លាស់នោះទេ ប៉ុន្តែហាក់ដូចជាពាក់ព័ន្ធនឹងលទ្ធភាពរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet ក្នុងការបំពេញកិច្ចដោយខ្លួនឯង ឬមុនពេលបានស្បថចូលកាន់តួនាទី។

---

[៣] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D56/3.1។ យោងតាមសេចក្តីសម្រេចទទួលស្គាល់មេធាវីពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D58 កថាខណ្ឌទី ៣ សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងនៅឡើយ រហូតដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ តាមរយៈសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ស្តីពីការដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ២០០៩។

[៤] *សំណុំរឿង នួន ជា និងអ្នកដទៃទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សេចក្តីជូនដំណឹងស្តីពីការបិទបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D13។

[៥] សេចក្តីប្រកាសព័ត៌មាន *សេចក្តីប្រកាសព័ត៌មានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១១។

[៦] ដីកាសម្រេចស្តីពីការបើកការស៊ើបអង្កេតឡើងវិញ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ២០១១ ឯកសារ D28។

6. នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា បានសម្រេចមិនតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[៨]។

7. នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានផ្តល់ការយល់ឃើញរបស់ខ្លួនលើការខ្វែងយោបល់គ្នានេះ។ ចៅក្រមអន្តរជាតិបានពន្យល់ថា ប្រធានអង្គបុរេជំនុំជម្រះបានបញ្ជូនឯកសារនានាពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នានេះត្រឡប់ទៅវិញ ដោយសំអាងលើហេតុផលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet ដែលមិនទាន់ទទួលបានការតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះ មិនមានសម្បទាក្នុងការដាក់ការខ្វែងយោបល់គ្នានោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណា ចៅក្រមអន្តរជាតិបានបញ្ជាក់ក្នុងយោបល់ដោយឡែករបស់ខ្លួនថា ការខ្វែងយោបល់គ្នានេះអាចទទួលយកបាន ហើយៈ

> “យោងតាមមាត្រា ២៣ ថ្មី នៃច្បាប់អ.វ.ត.ក សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ (ពីចៅក្រមយ៉ាងតិចបួនរូប) មានន័យថាដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ត្រូវមានសុពលភាព ឬ មានន័យថា ដីកា ឬ កិច្ចស៊ើបសួរដែលបម្រុងនឹងធ្វើដោយសហចៅក្រមស៊ើបអង្កេតម្នាក់ត្រូវតែយកមកអនុវត្ត។” ក្នុងសំណុំរឿងនាពេលនេះ មានន័យថា ដីកាបង្គាប់ដែលស្នើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងត្រូវតែយកមកអនុវត្ត។[៩]

8. នៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet បានដាក់ពាក្យសុំលាលែងពីការងារត្រឹមថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២[១០]។

9. នៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១២ ចៅក្រម Mark Harmon ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[១១]។

---

[៨] សេចក្តីប្រកាសព័ត៌មាន អ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីកម្ពុជា ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០១២ អាចរកបាននៅលើគេហទំព័រ http://www.un.org/sg/statements/?nid=5815។

[៩] មតិយោបល់របស់ចៅក្រម Downing និងចៅក្រម Chung នៃអង្គបុរេជំនុំជម្រះ ស្តីពីការខ្វែងយោបល់គ្នារវាង សហចៅក្រមស៊ើបអង្កេតតាមវិធានផ្ទៃក្នុង ចុះថ្ងៃទី ១០ ខែ ខែកុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៥០។

[១០] សេចក្តីប្រកាសព័ត៌មាន *សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង* ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២។

[១១] សេចក្តីប្រកាសព័ត៌មាន *ការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី* ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២។

10. នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ក.ស.ច.ស បានចេញសេចក្តីប្រកាសព័ត៌មានមួយ។ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង បានបញ្ជាក់ថា៖

សហចៅក្រមស៊ើបអង្កេតជាតិ សូមបញ្ជាក់ថា៖

- បន្ទាប់ពីការជូនដំណឹងអំពីការបិទការស៊ើបសួរតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ដោយសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១
- បន្ទាប់ពីបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះត្រូវបានសម្រេចរួចរាល់នៅថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១១ និង
- បន្ទាប់ពីការមកដល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark B. Harmon (ដែលជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមាននីតិសម្បទាគ្រប់គ្រាន់) សហចៅក្រមស៊ើបអង្កេតជាតិ ដោយបានធ្វើកំណត់ហេតុខ្វែងយោបល់នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៣ បានបញ្ជូនដីកាពិនិត្យមូលទៅការិយាល័យសហព្រះរាជអាជ្ញា ដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពរ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង។

នៅទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាអន្តរជាតិ បន្ទាប់ពីធ្វើការខ្វែងយោបល់គ្នាជាមួយសហព្រះរាជអាជ្ញាជាតិ បានបញ្ជូនសេចក្តីសន្និដ្ឋានឆ្លើយតបរបស់ខ្លួនទាក់ទងនឹងសំណុំរឿង ០០៣ មកសហចៅក្រមស៊ើបអង្កេត។

សហចៅក្រមស៊ើបអង្កេតជាតិសូមគូសបញ្ជាក់ថា ខ្លួននឹងបន្តចំណាត់ការនីតិវិធីដែលមានចែងក្នុងវិធានផ្ទៃក្នុងនៅក្នុងពេលសមស្រប ប៉ុន្តែខ្លួននឹងទទួលយកមកពិចារណាផងដែរ នូវសេចក្តីសន្និដ្ឋានផ្សេងៗទៀតរបស់សហព្រះរាជអាជ្ញាដែលអាចធ្វើឡើងក្នុងរយៈពេល ០៣ ខែ គិតចាប់ពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៣។

ផ្ទុយពីនេះ សហចៅក្រមស៊ើបអង្កេត Harmon បានបញ្ជាក់ នៅក្នុងសេចក្តីប្រកាសព័ត៌មានដដែលនេះថា៖ "អនុលោមតាមវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអន្តរជាតិសូមបញ្ជាក់ថា សំណុំរឿង ០០៣ នៅតែបើកដំណើរការ ហើយការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋកំពុង [អាចខុស] តែដំណើរការ"។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេត Harmon បានផ្តល់ព័ត៌មានដល់សាធារណជនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមការចោទប្រកាន់ និងនីតិវិធីដើម្បីធ្វើជាសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬ ដើមបណ្តឹង[១២]។

---

[១២] សេចក្តីប្រកាសព័ត៌មាន *សេចក្តីថ្លែងការណ៍ដោយសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងសំណុំរឿង ០០២* ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៣។

11. ចាប់តាំងពីសហមេធាវីត្រូវបានតែងតាំងឲ្យធ្វើជាតំណាងឲ្យលោក មាស មុត មក មានតែសហចៅក្រមស៊ើបអង្កេត Harmon តែម្នាក់ឯង ដែលបានដោះស្រាយរាល់សារណាដែលបានដាក់ដោយសហមេធាវី ឬសារណាដែលពាក់ព័ន្ធផ្សេងៗទៀត។

## II. ច្បាប់ជាធរមាន

12. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាតម្រូវឲ្យ អ.វ.ត.ក "ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញានានាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងកុមារ"[១៣]។ អនុសញ្ញាមួយដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ក្នុងចំណោមអនុសញ្ញាទាំងនោះ គឺ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[១៤]។

13. មាត្រា ១២(២) នៃកិច្ចព្រមព្រៀង[១៥] បានចែងថា "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ"។

14. មាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក[១៦] ចែងថា "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃ

---

[១៣] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្ម និងប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ លើវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាដទៃទៀតពីជំពូកទី៨ ដល់ ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩ (រដ្ឋធម្មនុញ្ញកម្ពុជា)។

[១៤] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័ត និងបើកឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាប្រទេសហត្ថលេខី ដោយសេចក្តីសម្រេច ២២០០ A (XXI) របស់មហាសន្និបាតអង្គការសហប្រជាជាតិចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៦ តាមមាត្រា ៤៩។

[១៥] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។

[១៦] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់អ.វ.ត.ក")។

ច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ”។

**ក. សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់**

15. សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ គឺជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋាន ដែលមានចែងក្នុងកតិកាសញ្ញា ICCPR។ មាត្រា ១៤(៣)(ខ) ចែងថា ក្នុងការសម្រេចសេចក្តីចោទប្រកាន់ណាមួយមកលើខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិ “មានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង”។

16. មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង ចែងថា សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញា ICCPR នេះ ត្រូវតែគោរពតាមនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការជំនុំជម្រះក្តី។ “សិទ្ធិបែបនេះ ជាពិសេស រួមមាន៖ ... សិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន...”។

17. មាត្រា ៣៥ថ្មី នៃច្បាប់ អ.វ.ត.ក បានចែងថា នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា សមស្របតាមមាត្រា ១៤ នៃកតិកាសញ្ញា ICCPR ក្នុងនោះរួមមានសិទ្ធិ “មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន...”។

**ខ. សិទ្ធិទទួលបានព័ត៌មានពីចរិតលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់**

18. សិទ្ធិទទួលបានព័ត៌មានពីការចោទប្រកាន់ គឺជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋាន ដែលមានចែងក្នុងកតិកាសញ្ញា ICCPR។ មាត្រា ១៤(៣)(ក) ចែងថា ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាន “ព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ”។

19. មាត្រា ៣៥ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា សមស្របតាមមាត្រា ១៤ នៃកតិកាសញ្ញា ICCPR ក្នុងនោះរួមមានសិទ្ធិ “ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បាន អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន”។

**គ. សិទ្ធិទទួលបានសមភាពនៃកម្លាំង**

20. សិទ្ធិទទួលបានសមភាពនៃកម្លាំងនេះ គឺជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋាន ដែលមានចែងក្នុងកតិកាសញ្ញា ICCPR។ មាត្រា ១៤(១) ចែងថា “ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបាន

ការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ"។ យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស ដែលជាស្ថាប័នអ្នកជំនាញឯករាជ្យមួយ ដែលតាមដានការអនុវត្តកតិកាសញ្ញា ICCPR ដោយរដ្ឋជាភាគី (ដូចជាប្រទេសកម្ពុជាជាដើម)៖[១៧] "ទស្សនទាននៃ 'ការកាត់សេចក្តីដោយយុត្តិធម៌' នៅក្នុងអត្ថន័យនៃមាត្រា ១៤ កថាខណ្ឌទី១....ក្នុងនោះរួមមាន...ការគោរពគោលការណ៍សមភាពនៃកម្លាំង..." [១៨]។

21. វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុងចែងថា "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ..."។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានទទួលស្គាល់ថា "ចរិតលក្ខណៈជាមូលដ្ឋាននៃគោលការណ៍ [សមភាពនៃកម្លាំង] ត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង..."[១៩]។

**ឃ. សិទ្ធិទទួលបានប្រព្រឹត្តកម្មដោយសមភាព**

22. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាចែងថា "ពលរដ្ឋខ្មែរគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់..."។

---

[១៧] *សូមមើល* ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គណៈកម្មាធិការសិទ្ធិមនុស្ស អាចរកបាននៅលើគេហទំព័រ: http://www2.ohchr.org/english/bodies/hrc/។ កម្ពុជាបានចុះហត្ថលេខាលើកតិកាសញ្ញា ICCPR នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ១៩៨០ និងបានចូលជាសមាជិកនៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៩២។ *សូមមើល* កម្រងសន្ធិសញ្ញាអង្គការសហប្រជាជាតិ នៅលើគេហទំព័រ http://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-4&chapter=4&lang =en#3។

[១៨] *Fei ទល់នឹង ប្រទេសកូឡុំប៊ី* ទំនាក់ទំនងលេខ ៥១៤/១៩៩២ ឯកសារអង្គការសហប្រជាជាតិ CCPR/C/53/D/514/1992 (1995) កថាខណ្ឌ ៨.៤។

[១៩] *សំណុំរឿង កាំង ហ្គិកអ៊ាវ* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ស.ដ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ E90 កថាខណ្ឌទី៥។ ដូចគ្នានេះដែរ នៅតុលាការ ICTY សិទ្ធិទទួលបានសមភាពនៃកម្លាំងត្រូវបានសម្រេចថាជា "ស្នូលនៃការធានាការកាត់សេចក្តីដោយយុត្តិធម៌"។ *ព្រះរាជអាជ្ញា ទល់នឹង Tadić* IT-94-1-A សាលក្រម ចុះថ្ងៃទី ១៥ កក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ៤៤។ *សូមមើលផងដែរ ព្រះរាជអាជ្ញា ទល់នឹង Delalić និងអ្នកដទៃទៀត* IT-96-21-T សេចក្តីសម្រេចលើសំណើរបស់ព្រះរាជអាជ្ញាសុំឱ្យចេញដីកាបង្គាប់ឱ្យមេធាវីការពារក្តីបង្ហាញសាក្សីជាមុន ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ កថាខណ្ឌ ៤៥ ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាសមភាពនៃកម្លាំងគឺជា "លក្ខខណ្ឌវិនិច្ឆ័យដ៏សំខាន់បំផុតនៃការកាត់សេចក្តីដោយយុត្តិធម៌។ គោលការណ៍នេះតម្រូវឱ្យរក្សានូវតុល្យភាពសមស្របរវាងភាគីនានា និងអនុវត្តចំពោះទាំងសំណុំរឿងរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌ"។

23. សិទ្ធិទទួលបានប្រព្រឹត្តិកម្មដោយសមភាពនេះ គឺជាសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ជាមូលដ្ឋាន ដែលមានចែងក្នុងកតិកាសញ្ញា ICCPR។ មាត្រា ១៤(១) ចែងថា "ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី"។ មាត្រា ២៦ ចែងថា "ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការការពារពីច្បាប់ស្មើៗគ្នា ដោយឥតរើសអើង"។

24. មាត្រា៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"។

## III. ឧទ្ធរណ៍

25. ក្រុមមេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យចូលមើលសំណុំរឿងទេ[២០]។ មេធាវីទទួលបានតែព័ត៌មានតិចតួចទាក់ទងនឹងស្ថានភាពនៃការស៊ើបអង្កេតតាមរយៈសេចក្តីប្រកាសព័ត៌មានម្តងម្កាល និងរបាយការណ៍ប្រចាំខែរបស់តុលាការតែប៉ុណ្ណោះ។ ក្រុមមេធាវីការពារក្តីមិនបានដឹងច្បាស់លាស់ទេ ថាតើការស៊ើបអង្កេតនៅបើកនៅឡើយ ឬបិទទៅហើយនៅពេលនេះ។ ក្រុមមេធាវីការពារក្តីមិនបានដឹងថាតើអង្គបុរេជំនុំជម្រះ បានដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតហើយឬនៅ។ ជាងនេះទៅទៀត ក្រុមមេធាវីការពារក្តីមិនបានដឹងសូម្បីតែពីមូលហេតុពិតប្រាកដដែលសហចៅក្រមស៊ើបអង្កេតខ្វែងយោបល់គ្នាផង។

26. ស្ថានភាពបែបនេះមិនអាចទទួលយកបានទេ។ វារំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចជា សិទ្ធិទទួលបានពេលវេលា និងសម្ភាររូបវន្តគ្រប់គ្រាន់ សិទ្ធិទទួលបានការប្រាប់ពីចរិតលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់ប្រឆាំងខ្លួន សិទ្ធិទទួលបានសមភាពនៃកម្លាំង និងសិទ្ធិទទួលបានប្រព្រឹត្តិកម្មដោយសមភាព។ ក្រុមមេធាវីការពារក្តីទាមទារឲ្យមានការបំភ្លឺ និងការផ្តល់បច្ចុប្បន្នភាពទៀងទាត់ និងទាន់ពេលវេលាទាក់ទងនឹងស្ថានភាពនៃការស៊ើបអង្កេត ដើម្បីឲ្យក្រុមមេធាវីអាចមានលទ្ធភាពបំពេញកិច្ចការពារសិទ្ធិរបស់លោក មាស មុត ដោយវិរិយភាព[២១]។

---

[២០] *សូមមើល* សំណើសុំរបស់ មាស មុត សុំការអនុញ្ញាតចូលមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៣ ឯកសារ D82។

[២១] វចនានុក្រម Black's Law Dictionary កំណត់និយមន័យពាក្យថា វិរិយភាពថាជា "ការបំពេញកិច្ចការងារមួយដ៏សមហេតុផលដែលបុគ្គលណាម្នាក់គួរធ្វើ ឬត្រូវធ្វើឡើងជាធម្មតា ដោយការសង្វាតព្យាយាម ដើម្បីឆ្លើយតបទៅលក្ខខណ្ឌផ្លូវច្បាប់ ឬដើម្បីអនុវត្តកាតព្វកិច្ចមួយ"។ Black's Law Dictionary ទំព័រ ៤៦៨ (បោះពុម្ពលើកទី៧ ឆ្នាំ១៩៩៩)។ តុលាការ ICTY បាន

***សិទ្ធិទទួលបានពេលវេលា និងសម្ភារគ្រប់គ្រាន់***

27. សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានពេលវេលា និងសម្ភារគ្រប់គ្រាន់ ត្រូវបានរំលោភ ដោយសារកង្វះព័ត៌មាន ដែលគាត់ត្រូវមាននាពេលបច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងស្ថានភាពនៃការស៊ើបអង្កេតរបស់តុលាការ។ ប្រសិនបើការស៊ើបអង្កេតត្រូវបានបិទបញ្ចប់ ហើយ ក.ស.ព ចេញដីកាសន្និដ្ឋានស្ថាពរ ដោយមិនបានប្រាប់លោក មាស មុត ក្រុមមេធាវីការពារក្តីប្រាកដជាមិនអាចឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនេះក្នុងពេលកំណត់បានទេ។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ហើយថា ក្រុម មេធាវីការពារក្តីមានសិទ្ធិឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព[២២]។ ប្រសិនបើ ក.ស.ច.ស បិទការស៊ើបអង្កេតដោយគ្មានការចោទប្រកាន់ណាមួយលើលោក មាស មុត ដូចដែលសហចៅក្រម ស៊ើបអង្កេត យូ ប៊ុនឡេង បានធ្វើកន្លងមក នោះ ក.ស.ព អាចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំកល់រឿង មិនចាត់ការនេះ។ ប្រសិនបើរឿងនេះកើតឡើងមែន ក្រុមមេធាវីប្រាកដជាមិនអាចឆ្លើយតបទៅនឹង បណ្តឹងឧទ្ធរណ៍នេះបានទេ ព្រោះក្រុមមេធាវីមិនបានដឹងអ្វីទាំងអស់នេះពីសហចៅក្រមស៊ើបអង្កេតទេ។ គ្មានមន្ទិលសង្ស័យទេថា វាជាប្រយោជន៍ដ៏សំខាន់របស់លោក មាស មុត ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍បែបនេះ ព្រោះវានឹងកំណត់ថា តើលោក មាស មុត នឹងត្រូវបញ្ជូនទៅជំនុំជម្រះ ឬ សំណុំរឿងរបស់គាត់នឹងត្រូវបានដំកល់ទុកមិនចាត់ការ។

---

បញ្ជាក់ថា គោលបំណងនៃការផ្តល់ដល់ជនជាប់ចោទនូវសិទ្ធិមួយចំនួននៅក្រោមលក្ខន្តិកៈតុលាការ ICTY "គឺថា ជនជាប់ចោទគួរប្រើប្រាស់នូវវិរិយភាពនេះក្នុងការអនុវត្តសិទ្ធិទាំងអស់នេះ"។ ចៅក្រម Richard May និង ចៅក្រម Marieke Wierda ភស្តុតាងព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ៣០៦ (គ្រឹះស្ថានបោះពុម្ព Transnational Publishers Inc., 2002) *ការពិភាក្សាវែកញែករវាងព្រះរាជអាជ្ញា ទល់នឹង Tadić* IT-94-1-A សេចក្តីសម្រេចលើសំណើរបស់ដើមបណ្តឹងឧទ្ធរណ៍សុំពន្យារពេលកំណត់ និងការទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៨។

[២២] *សូមមើល សំណុំរឿងរបស់ នួន ជា និងអ្នកដទៃទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ដែលបដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោកអៀង សារី ទៅនឹងការសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4។

***សិទ្ធិទទួលបានព័ត៌មានពីចរិតលក្ខណៈ និងបុព្វហេតុនៃការការចោទប្រកាន់មកលើគាត់***

28. សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានព័ត៌មានពីចរិតលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់មកលើរូបគាត់ ត្រូវបានរំលោភ ដោយសារកង្វះព័ត៌មានដែលគាត់ត្រូវមាននាពេលនេះ ទាក់ទងនឹងស្ថានភាពនៃការស៊ើបអង្កេតរបស់តុលាការ។ ដូចចៅក្រម Trechsel បានពន្យល់ថា "គេមិនគួររំពឹងថា ជនជាប់ចោទត្រូវធ្វើការស្មានលេងៗចំពោះការចោទប្រកាន់មកលើខ្លួនឡើយ"[២៣]។ បើសិនមិនមានព័ត៌មានដែលបានស្នើសុំ ហើយមិនមានសិទ្ធិចូលមើលសំណុំរឿងទៀតនោះ នោះមេធាវីពិតជាគ្មានជម្រើសអ្វី ក្រៅតែពីការស្មានពីអ្វីដែលនឹងអាចកើតមានឡើងចំពោះកូនក្តីរបស់ខ្លួននោះឡើយ។

29. សិទ្ធិទទួលបានព័ត៌មានភ្លាមៗ និងលម្អិតពីចរិតលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់មកលើរូបគាត់ អនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ពោលគឺមិនមែនទាល់តែលោកមាស មុត ត្រូវបានចោទប្រកាន់ជាផ្លូវការនោះទេ។ យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស សិទ្ធិនេះមានចាប់តាំងពី "អំឡុងពេលស៊ើបអង្កេត ដែលតុលាការ ឬស្ថាប័នអយ្យការ សម្រេចចាត់វិធានការនីតិវិធីលើជនណាម្នាក់ ដែលត្រូវបានសង្ស័យពីឧក្រិដ្ឋកម្មណាមួយ ឬស្ថានប័ននេះប្រកាសឈ្មោះជននោះជាសាធារណៈថាជាជនសង្ស័យ"[២៤]។

30. លោក មាស មុត ត្រូវបានកំណត់ឈ្មោះយ៉ាងច្បាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ យុត្តិសាស្ត្ររបស់ ក.ស.ច.ស កន្លងមក បានបង្ហាញថា ជនទាំងឡាយណាដែលមានឈ្មោះនៅក្នុងដីកា

---

[២៣] សូមមើល STEFAN TRECHSEL សិទ្ធិមនុស្សក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ទំព័រ ២០៣ (បោះពុម្ពផ្សាយដោយ Oxford University Press ឆ្នាំ២០០៥)៖ "ទោះបីជាសន្មត់ថា កំហុសឆ្គងការងារមួយដែលកើតមានឡើង នៅក្នុងការធ្វើសេចក្តីព្រាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការបកស្រាយដោយសុភវិនិច្ឆ័យមួយលើមាត្រា ៦(៣)(ក) [នៃអនុសញ្ញាអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដែលចែងថា ជនជាប់ចោទមានសិទ្ធិទទួលបានព័ត៌មានភ្លាមៗ ដោយលម្អិត និងជាភាសាដែលខ្លួនយល់ អំពីបុព្វហេតុ និងចរិតលក្ខណៈនៃការចោទប្រកាន់ប្រឆាំងមកលើខ្លួននេះ] តម្រូវយ៉ាងច្បាស់ថា មាត្រានេះត្រូវតែអនុវត្តយ៉ាងម៉ឺងម៉ាត់ ហើយគេមិនត្រូវទុកឲ្យជនជាប់ចោទធ្វើការស្មានលេងៗនោះទេ។ ផលវិបាកនៃកំហុសឆ្គងទាំងនោះ ត្រូវតែជាការទទួលខុសត្រូវរបស់អ្នកដែលបានប្រព្រឹត្ត។ វាជាការមិនអាចទទួលយកបានទេ ដែលជនជាប់ចោទត្រូវទទួលខុសត្រូវបង់ខាតលើកំហុសឆ្គង ដែលបង្កឡើងដោយព្រះរាជអាជ្ញា"។ ក្រុមមេធាវីសូមលើកឡើងថា ក្នុងកាលៈទេសៈទាំងនេះ គោលការណ៍នេះអនុវត្តដូចគ្នា ចំពោះ ក.ស.ច.ស ដូចដែលអនុវត្តចំពោះ ក.ស.ព នៅក្នុងកាលៈទេសៈដទៃទៀតដែរ។

[២៤] គណៈកម្មការសិទ្ធិមនុស្ស យោបល់ទូទៅលេខ ១៣ មាត្រា ១៤ (សម័យប្រជុំលើកទី២១ ឆ្នាំ១៩៨៤) កម្រងយោបល់ទូទៅ និងអនុសាសន៍ទូទៅ អនុម័តដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ ឯកសារលេខ **HRI/GEN/1/Rev.1** ទំព័រ ១៤ (ឆ្នាំ១៩៩៤) កថាខណ្ឌទី៨ អាចរកបាននៅលើគេហទំព័រ http://www1.umn.edu/humanrts/gencomm/hrcom13.htm។

សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជា "ជនត្រូវចោទ"[២៥]។ កិច្ចដំណើរការនីតិវិធីនានាត្រូវបានធ្វើឡើងរួចហើយប្រឆាំងនឹងលោក មាស មុត។ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានចេញសេចក្តីសម្រេចមួយ ដោយបញ្ជាក់យ៉ាងច្បាស់ថា លោក មាស មុត ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ហើយវាស្ថិតនៅក្រោមអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវធ្វើការស៊ើបអង្កេតលើរូបគាត់[២៦]។ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងរូបនេះ ក៏បានជូនដំណឹងដល់លោក មាស មុត ថា គាត់ស្ថិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការ ហើយចៅក្រមក៏បានណែនាំគាត់ពីសិទ្ធិនានារបស់គាត់[២៧]។ បើទោះបី ក.ស.ច.ស មិនទាន់កំណត់ឈ្មោះ លោក មាស មុត ជា ជនសង្ស័យ/ជនត្រូវចោទ ជាផ្លូវការក៏ដោយ ក៏គាត់ត្រូវបានគេប្រកាសឈ្មោះជាសាធារណៈរួចទៅហើយ។ នៅពេលដែលបុគ្គលិកម្នាក់របស់ អ.វ.ត.ក បានធ្វើឲ្យលេចព័ត៌មានពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដល់សារព័ត៌មាន ស្ថានភាពលោក មាស មុត ជាជនសង្ស័យ/ជនត្រូវចោទនេះ ត្រូវបានគេចុះផ្សាយក្នុងសារព័ត៌មានពាសពេញ ហើយរឿងក្តីនេះត្រូវបានគេដឹងឮជាទូទៅទៅហើយនៅក្នុងប្រទេសកម្ពុជា[២៨]។

31. ព័ត៌មានដែលអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet ផ្តល់ដល់លោក មាស មុត ថាគាត់ជាជនសង្ស័យ មិនគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងសិទ្ធិទទួលបានព័ត៌មានភ្លាមៗ និង លម្អិតពីចរិតលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់ទេ។ ចៅក្រម Kasper-Ansermet បានប្រាប់ លោក មាស មុត ជិតពីរឆ្នាំមុន អំពីឧក្រិដ្ឋកម្មនានា ដែលគាត់កំពុងត្រូវបានស៊ើបអង្កេត

---

[២៥] *សូមមើល សំណុំរឿងរបស់ នួន ជា និងអ្នកដទៃទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចការស្នើសុំការចោទប្រកាន់បន្ថែម ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D298/2 កថាខណ្ឌ ១៣។

[២៦] សេចក្តីសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបសួរពាក់ព័ន្ធនឹងជនសង្ស័យ ចុះថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D48។

[២៧] សេចក្តីជូនដំណឹងពីសិទ្ធិជនសង្ស័យ [វិធានផ្ទៃក្នុង ២១(១)(ឃ)] ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៦ ខែមីនា ឆ្នាំ២០១២ ឯកសារ D33។

[២៨] *សូមមើល ឧទាហរណ៍* អត្ថបទសរសេរដោយ Abby Seif ក្រោមចំណងជើង *បណ្តាញអ៊ិនធើណេតខូចធ្វើឲ្យលេចចេញព័ត៌មានសម្ងាត់របស់តុលាការខ្មែរក្រហម* សារព័ត៌មាន Phnom Penh Post ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១២ អាចរកបានលើគេហទំព័រ: http://www.phnompenhpost.com/national/faulty-link-reveals-khmer-rouge-courts-secret-documents: "ទោះបីឈ្មោះកម្មាភិបាលថ្នាក់កណ្តាលទាំង ៥ នាក់ ដែលត្រូវបានដាក់ចូលក្នុងបញ្ជីជាជនសង្ស័យក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលរដ្ឋាភិបាលជំទាស់នោះ ត្រូវបានគេដឹងឮជាទូទៅ ហើយបានក្លាយជាព័ត៌មានសាធារណៈជាច្រើនឆ្នាំមកហើយក្តី ក៏តុលាការនៅតែបដិសេធមិនបញ្ចេញឈ្មោះរបស់ពួកគេជាសាធារណៈ"។

និងក្នុងអំឡុងពេលដែលគេសង្ស័យថា ឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តិឡើង[២៩]។ មិនមានតំរុយណាមួយដែល ចៅក្រម Kasper-Ansermet បានប្រាប់ទៅលោក មាស មុត ពីការចោទប្រកាន់នានាដែលអាចមាន ឬពីអង្គហេតុណាមួយដែលគាំទ្រដល់ការចោទប្រកាន់ទាំងនេះទេ។ មិនមានការផ្តល់បច្ចុប្បន្នភាពណាមួយ តាំងពីពេលនោះមក ដល់លោក មាស មុត ថាតើគាត់នៅតែស្ថិតនៅក្រោមការស៊ើបអង្កេតដដែលឬយ៉ាងណា ហើយពីឧក្រិដ្ឋកម្មអ្វីនោះទេ។

32. ការស៊ើបអង្កេតលើសំណុំរឿង ០០៣ បានចាប់ផ្តើមជាងបួនឆ្នាំកន្លងមកហើយ។ លោក មាស មុត ត្រូវបានជូនដំណឹងជាផ្លូវការពីឋានៈរបស់គាត់ជាជនសង្ស័យមួយរូបជិតពីរឆ្នាំមុន។ សេចក្តីប្រកាសព័ត៌មានចុងក្រោយពាក់ព័ន្ធនឹងសំណុំរឿង ០០៣ នេះ ត្រូវបានចេញផ្សាយក្នុងខែកុម្ភៈ ឆ្នាំ២០១៣ ដែលមានរយៈពេលជិតមួយឆ្នាំមុន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ លោក មាស មុត ត្រូវបានដាក់ទាំងស្រុង ឲ្យស្ថិតនៅក្នុងស្ថានភាពងងឹតទាក់ទងនឹងស្ថានភាពនៃការស៊ើបអង្កេតនេះ។ គាត់មិនដឹងសូម្បីតែថាតើ ការស៊ើបអង្កេតនេះនៅបើកនៅឡើយ ឬបានបិទទៅហើយទេនៅពេលនេះ។ ការខ្វះព័ត៌មានអំពីកិច្ចដំណើរការនីតិវិធីដែលកំពុងបន្តនេះ ធ្វើឲ្យលោកមាស មុត មានការតឹងតែងក្នុងអារម្មណ៍ និងត្រូវគិតគូរច្រើន។

### *សិទ្ធិទទួលបានសមភាពនៃកម្លាំង*

33. សិទ្ធិទទួលបានសមភាពនៃកម្លាំងរបស់លោក មាស មុត ត្រូវបានរំលោភ ដោយសារកង្វះព័ត៌មាន ដែលគាត់មាននាពេលបច្ចុប្បន្ននេះ ទាក់ទងនឹងស្ថានភាពនៃការស៊ើបអង្កេតរបស់តុលាការ។ ក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិចូលមើលសំណុំរឿង ដូច្នេះភាគីទាំងពីរនេះអាចមានព័ត៌មានច្រើនជាងក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងស្ថានភាពបច្ចុប្បន្ននៃការស៊ើបអង្កេត។ វិធាន ៦៦(៤) ចែងថាសំណុំរឿងត្រូវបញ្ជូនទៅ ក.ស.ព នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានសម្រេចបិទបញ្ចប់ការស៊ើបអង្កេត ហើយរយៈពេលសម្រាប់ដាក់សំណើសុំការស៊ើបសួរបន្ថែមបានកន្លងផុត។ ដូច្នេះ ក.ស.ព នឹងមានព័ត៌មានទាក់ទងស្ថានភាពនៃការស៊ើបអង្កេត ដែលក្រុមមេធាវីនឹងមិនអាចមាន លើកលែងតែសហចៅក្រមស៊ើបអង្កេតសម្រេចផ្តល់ដំណោះស្រាយតាមការស្នើសុំដូចមានក្នុងសំណើនេះ។

---

[២៩] *សូមមើល* សេចក្តីជូនដំណឹងពីសិទ្ធិជនសង្ស័យ (វិធាន ២១(១)(ឃ) ក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី ៦ ខែមីនា ឆ្នាំ២០១២ ឯកសារ D33។

*សិទ្ធិទទួលបានប្រព្រឹត្តកម្មដោយសមភាព*

34. សិទ្ធិទទួលបានប្រព្រឹត្តកម្មដោយសមភាពរបស់លោក មាស មុត ត្រូវបានរំលោភ ដោយសារការខ្វះព័ត៌មានដែលគាត់មាននាពេលបច្ចុប្បន្ន ទាក់ទងនឹងស្ថានភាពនៃការស៊ើបអង្កេតរបស់តុលាការ។ កាំង ហ្គេក អ៊ាវ នួន ជា ខៀវ សំផន អៀង សារី និង អៀង ធីរិទ្ធ សុទ្ធតែត្រូវបានផ្តល់ព័ត៌មាន ពេញលេញ ទាក់ទងនឹងចរិតលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់លើពួកគេ។ ពួកគេមានសិទ្ធិចូល មើលសំណុំរឿង និងត្រូវបានជូនដំណឹងពីវិធានការនីតិវិធីនានា ដែលត្រូវធ្វើក្នុងអំឡុងពេលស៊ើបអង្កេត ដូចជាការបិទការស៊ើបអង្កេត និងការចេញដីកាដំណោះស្រាយ ជាដើម។ ផ្ទុយទៅវិញ លោក មាស មុត ស្ទើរតែគ្មានទទួលបានព័ត៌មានអ្វីសោះ។ ប្រព្រឹត្តកម្មខុសគ្នាស្រឡះបែបនេះ ត្រូវបានកត់សម្គាល់ ជាមួយនឹងក្តីបារម្ភកាលពីជាងពីរឆ្នាំមុន ដោយចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដែលបានបញ្ជាក់ថា៖

> "ទោះបីជាសហចៅក្រមស៊ើបអង្កេតមានអំណាចឆន្ទានុសិទ្ធិជាក់លាក់ ក្នុងការចេញសេចក្តីសម្រេច ដើម្បីជូនដំណឹងជាផ្លូវការពីបទចោទដល់បុគ្គល ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតពុំបានផ្តល់ការពន្យល់ណាមួយនៅក្នុងសំណុំរឿងនេះ ឬពុំបានផ្តល់ការពន្យល់ពីមូលហេតុដែលធ្វើឲ្យខ្លួនអនុវត្តការងារក្នុងសំណុំរឿង 00៣ ខុសពីរឿងក្តីមុនៗ និងពីមូលហេតុដែលជនសង្ស័យមិនត្រូវបានគេជូនដំណឹងពីស្ថានភាពរបស់ខ្លួននៅក្នុងកិច្ចស៊ើបសួរនោះដែរ។ ចំណុចនេះអាចត្រូវបានចាត់ទុកថាមានបញ្ហា..."[៣0]

មានការប្រែប្រួលតិចតួចណាស់តាំងពីពេលនោះមក។

## IV. សេចក្តីសន្និដ្ឋាន

35. វិធាន ២១ នៃវិធានផ្ទៃក្នុង ចែងច្បាស់ថា "ច្បាប់អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ... ក្នុងន័យនេះ៖ ក. ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែយុត្តិធម៌ និងមានតម្លាភាព..."។ កិច្ចដំណើរការនីតិវិធីនាពេលនេះមិនមានតម្លាភាពទេ ផ្ទុយទៅវិញ វាពោរពេញដោយ

---

[៣0] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក រ៉ូប៊ឺត ហាមីល (Robert Hamill) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២0១១ ឯកសារ D11/2/4/4 កថាខណ្ឌ ៣។

ភាពធងន់ធ្ងន់។ ក្រុមមេធាវីការពារក្តី ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ធ្វើការបំភ្លឺពីស្ថានភាពនៃការស៊ើបអង្កេតបច្ចុប្បន្ន និងប្រាប់មកក្រុមមេធាវីការពារក្តីពីការប្រែប្រួលណាមួយលើស្ថានភាពនេះ។

36. ក្រុមមេធាវីស្នើសុំថា ការបំភ្លឺណាមួយដែលផ្តល់ឲ្យជាការឆ្លើយតបទៅនឹងសំណើសុំនេះ ត្រូវធ្វើជាសាធារណៈ។ អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌ក្នុងសង្គមបើកទូលាយ (The Open Society Justice Initiative) ថ្មីៗនេះ បានទាមទារឲ្យមានតម្លាភាពពាក់ព័ន្ធនឹងស្ថានភាពនៃសំណុំរឿង ០០៣ និង ០០៤៖

> ចំពោះការជំនុំជម្រះក្តីផ្នែកទីពីរក្នុងសំណុំរឿង ០០២ ទាំងតុលាការ ទាំងអង្គការសហប្រជាជាតិ ក៏ដូចជាប្រទេសផ្តល់ជំនួយ និងរដ្ឋាភិបាលកម្ពុជា គួរមានភាពស្មោះត្រង់ជាមួយសាធារណជនអំពីស្ថានភាពនៃសំណុំរឿងនេះ និងតួនាទីនៃការជ្រៀតជ្រែកនយោបាយ និងថាតើខ្លួននឹងបន្តកិច្ចដំណើរការចប់ចុងចប់ដើម ដោយមានសុច្ចរិតភាពតុលាការឬយ៉ាងណា... មកដល់ពេលបច្ចុប្បន្ននេះ តុលាការហាក់ខ្វះភាពជាអ្នកដឹកនាំប្រកបដោយបរិសកម្ម និងភាពច្នៃប្រឌិត នៅគ្រប់កម្រិតទាំងអស់ ក្នុងការធ្វើផែនការការងាររបស់ខ្លួន។ កង្វះខាតនេះកើតមានជាមួយនឹងកង្វះតម្លាភាព និងភាពស្មោះត្រង់អំពីតថភាពនៃស្ថានភាពជាក់ស្តែងបច្ចុប្បន្នផងដែរ។ វាជាការចាំបាច់បំផុតដែលអង្គការសហប្រជាជាតិ និងមន្ត្រីតុលាការជាន់ខ្ពស់ទាំងអស់ត្រូវប្រើប្រាស់ភាពជាអ្នកដឹកនាំលើបញ្ហាទាំងអស់នេះ[៣៩]។

37. មិនមានហេតុផលណាមួយដែលថា ព័ត៌មានដែលបានស្នើសុំនេះមិនអាចត្រូវបានផ្តល់ឲ្យទៅក្រុមមេធាវីការពារក្តី ភាគីដទៃទៀត និងសូម្បីតែសាធារណជននោះទេ។ ការផ្តល់ព័ត៌មាននេះនឹងមិនធ្វើឲ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការទេ (ទោះសំណុំរឿងនេះស្ថិតនៅក្នុងការស៊ើបអង្កេត ឬបានបិទបញ្ចប់ទៅហើយក្តី)។

**ហេតុដូច្នេះ** យោងតាមហេតុផលដូចដែលបានបញ្ជាក់ក្នុងសំណើសុំនេះ ក្រុមមេធាវីការពារក្តីសូមស្នើសហចៅក្រមស៊ើបអង្កេត មេត្តាធ្វើការ**បំភ្លឺ**អំពីស្ថានភាពនៃកិច្ចស៊ើបអង្កេតរបស់តុលាការ និងសូមមេត្តា**ប្រាប់**មកក្រុមមេធាវីការពារក្តីអំពីការប្រែប្រួលណាមួយលើស្ថានភាពនៃការស៊ើបអង្កេតនេះ។

សូមដាក់ជូនសហចៅក្រមស៊ើបអង្កេតមេត្តាពិនិត្យដោយក្តីគោរព។

---

[៣៩] ឯកសារគោលជំហររបស់អង្គការគំនិតផ្តួចផ្តើមសង្គមបើកទូលាយ (OSJI) *ការធ្វើផែនការ និងភាពជាអ្នកដឹកនាំត្រូវការជាចាំបាច់នៅពេលនេះនៅអ.វ.ត.ក* ចេញផ្សាយក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ទំព័រ ៥-៦ អាចរកបាននៅគេហទំព័រ: http://www.opensocietyfoundations.org/sites/default/files/cambodia-eccc-position-11032013.pdf។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៣០** ខែ **ធ្នូ** ឆ្នាំ **២០១៣**
សហមេធាវីការពារក្តីលោក មាស មុត

| | |
|---|---|
| **អាង ឧត្តម** | **Michael G. KARNAVAS** |